ការសម្ភាសរបស់បងស្រី ទិត្យ ដែនចាន់

កៈ អ្នកសម្ភាស Matt Boyd និង កែវ សុម៉ាលី ខៈ ទិត្យ ដែនចាន់

កៈ ថ្ងៃហ្នឹងគឺជាថ្ងៃគឺ ១០ ខែ២ ឆ្នាំ ២០១៦ បងស្រីឈ្មោះអីដែរ ឈ្មោះពេញ?

ខៈ ឈ្មោះ ទិត្យ ដែនចាន់។

កៈ ហើយខ្ញុំឈ្មោះ Matt Boyd

គៈ ខ្ញុំឈ្មោះ សុ ម៉ាលី

កៈ ហើយសម្រាប់ការសម្ភាសមួយហ្នឹង យើងធ្វើជាកិច្ចការរបស់ ប៊ី វាយ យូ គេចង់ជួយអភិរក្សពង្សប្រវត្តិខ្មែរ។ អញ្ចឹងការសម្ភាសមួយហ្នឹង គេចង់ផុសតាមវេបសាយគេ គេបង្កើតថ្មី ហើយសម្រាប់បងស្រីឯងអាចបើកវេបសាយមួយហ្នឹង ហើយស្តាប់ការសម្ភាសមួយហ្នឹង ហើយឃើញរូបថតអីផ្សេងៗទៀត។ ចឹងបងស្រីអនុញ្ញាតឱ្យយើងផុសការសម្ភាសមួយហ្នឹងតាមវេបសាយបានទេ?

ខៈ អូ! សម្ភាសពីអីគេ?

កៈ សួរពីជីវិត ដូចជាប្រវត្តិខ្លួនឯង ដូចជា...

ខៈ អូ! អត់អីបាន។

កៈ អូខេ!

ខៈ (សើច) ស្តាប់សិន។

កៈ ហើយយើងធ្វើនៅមណ្ឌលខាងត្បូង នៅភ្នំពេញ។ ហើយឈ្មោះពិតប្រាកដឈ្មោះថាម៉េចមិញ?

ខៈ ឈ្មោះខ្ញុំឈ្មោះ ទិត្យ ដែនចាន់។

កៈ ហើយឈ្មោះម៉ាក់ប៉ា គាត់ឈ្មោះអីដែរ?

ខ៖ ម៉ាក់ខ្ញុំគាត់ឈ្មោះ ទិត្យ ចាន់ស្រីពៅ ហើយប៉ាខ្ញុំគាត់ឈ្មោះ នួន មុនី។

ក៖ ហើយឈ្មោះតាយាយ ស្គាល់ឈ្មោះគាត់អត់?

ខ៖ ខ្ញុំស្គាល់ឈ្មោះ តា ហើយនិង យាយ។ តាខ្ញុំឈ្មោះ ហែម សយ ហើយយាយខ្ញុំគាត់ឈ្មោះ ទិត្យ។

ក៖ គាត់ខាងប៉ា ឬក៏ ខាងម៉ាក់?

ខ៖ ខ្ញុំហ៎?

ក៖ លោកតាលោកយាយមិញ!

ខ៖ អឺ...ខ្ញុំអត់យល់សំណួរហ្នឹង ខាងប៉ា ខាងម៉ាក់ម៉េច?

គ៖ ដូចថា តាខាងប៉ា ឬក៏តាខាងម៉ាក់? គាត់ចង់សួរ។

ខ៖ ខាងម៉ាក់

ក៖ ស្គាល់តាយាយខាងប៉ាអត់?

ខ៖ តាយាយខាងប៉ាគាត់នៅរស់ឡើយ។

ក៖ ហើយស្រុកកំណើតរបស់ចាន់នៅកន្លែងណាដែរ?

ខ៖ ខ្ញុំកើតនៅជាយដែនថៃ។

ក៖ ថៃហ៎?

ខ៖ ហ្នឹងហើយ កើតនៅជាយដែន ប្រទេសថៃ រវាងប្រទេសថៃ និង ប្រទេសខ្មែរ។ កើតនៅជាយដែនកំឡុងពេលប្រទេសខ្មែរមានសង្គ្រាមស៊ីវិល ជំនាន់ ប៉ុល ពត ហ្នឹង ម៉ាក់ខ្ញុំ ក្រុមគ្រួសារម៉ាក់ខ្ញុំ(ប្ដី) គាត់បានបែកគ្នា ចឹងម៉ាក់ខ្ញុំគាត់បានទៅជាយដែនប្រទេសថៃហ្នឹង។ អញ្ចឹងខ្ញុំបានកើតនៅហ្នឹង។

ក៖ នៅខេត្តណាដែរ?

ខ៖ អត់ដឹងទេ! យើងអត់ដឹងតំបន់ប្រទេសហ្នឹង គ្រាន់ថាម្ដុំជួរភ្នំដងរែក។ ប្រហែលជាព្រំប្រទល់ខេត្តស្វាយ...អីគេ បន្ទាយមានជ័យ ឧត្តរមានជ័យ ប៉ុនខ្ញុំអត់ដឹងខាងខេត្តណាប្រទេសថៃទេ យើងអត់បានដឹងទេ។

ក៖ ហើយអាយុប៉ុន្មានហើយ?

ខ៖ ខ្ញុំអាយុ៣២ឆ្នាំ។

ក៖ កើតនៅឆ្នាំប៉ុន្មានដែរ?

ខ៖ ឆ្នាំ១៩៨៥

ក៖ អញ្ជឹងចេះភាសាថៃដែរទេ?

ខ៖ អូ! អត់ចេះទេ ប៉ុន្តែចាប់អារម្មណ៍ភាសាហ្នឹង អត់ទាន់បានរៀន ប៉ុន្តែអាចយល់ខ្លះៗ។ អត់ចេះថៃផង។

ក៖ អូខេ! សួរសំណួរទៅ

គ៖ បងទាក់ទងនឹង...តើបងមានអ្វីជាការចងចាំនៅពេលដែលបងនៅពីក្មេងអត់បង?

ខ៖ ចងចាំទៅលើអីគេ?

គ៖ ទាក់ទងកាលបងនៅពេលក្មេងហា៎ តើមានអ្វីដែលធ្វើឱ្យបងសប្បាយរីករាយជាងគេ?

ខ៖ អូ! ការពិតពីក្មេងការចងចាំរបស់ខ្ញុំអត់សូវសប្បាយប៉ុន្មានទេ ដោយសារខ្ញុំកើតឡើងពីតូចខ្ញុំនៅក្នុងសង្គ្រាម អញ្ជឹងខ្ញុំរស់នៅជាយដែនថៃមែន តែខ្ញុំរស់នៅហ៊ុំព័ទ្ធដោយព្រៃ។ អញ្ជឹងខ្ញុំចាំបានកាលហ្នឹងម៉ាក់ខ្ញុំ គាត់បានប្ដូរតំបន់ពីកន្លែងមួយទៅកន្លែងមួយ។ អញ្ជឹងពួកយើងត្រូវដើរកាត់ព្រៃ អញ្ជឹងអ្វីដែលខ្ញុំចាំ ខ្ញុំបានដើរជាមួយម្ដាយខ្ញុំ ហើយមានគេហៅថាមេខ្យល់ម្នាក់ហ្នឹងគាត់អ្នកអ៊ីវខ្ញុំ។ អញ្ជឹងទាំងគេទាំងដឹងខ្លួន ខ្ញុំនៅលើខ្នងមេខ្យល់ហ្នឹងរហូត។ អញ្ជឹងអ្វីដែលខ្ញុំភ្ញាក់ឡើងក៏ឃើញព្រៃអីចឹង ប៉ុន្តែការចងចាំមួយគឺ...វាស្រពិចស្រពិល ប៉ុន្តែគ្រាន់តែការធ្វើដំណើរយើងភាគច្រើន យើងធ្វើដំណើរនៅតាមព្រៃ ឆ្លងពីតំបន់មួយទៅ... ពីខេត្តមួយទៅខេត្ត

មួយ។ នៅជាយខេត្តថៃយើងមានជម្រំ មានន័យថាជម្រំច្រើន យើងប្តូរពីជម្រំមួយទៅជម្រំមួយ។ អញ្ចឹងអ្វីដែលខ្ញុំចងចាំគឺការធ្វើដំណើរឆ្លងកាត់ព្រៃ ហើយខ្ញុំបានឃើញសត្វឃ្មុំឬក៏អីចឹង កាលខ្ញុំនៅក្មេង កាលហ្នឹងយុវវ័យរបស់ខ្ញុំ សប្បាយជាងគេនៅពេលដែលនៅជម្រំដែលខ្ញុំរស់នៅហ្នឹង គេអឺ...ធម្មតាវាជាជម្រំដាច់ស្រយាល ហើយយើងបានទទួលការឧបត្ថម្ភពីយូអិន (UN) អញ្ចឹងភាគច្រើនគេឱ្យអាហារពួកយើង អញ្ចឹងរាល់ថ្ងៃអង្គារយើងទៅបើកអាហារហើយ អញ្ចឹងអ្វីដែលសំខាន់គេមានសម្តែងល្ខោនឱ្យមើល អញ្ចឹងខ្ញុំចូលចិត្តមើលល្ខោន នៅពេលដែលយើងទៅបើកអាហារ នៅពេលដែលយើងស្នាក់នៅជម្រំហ្នឹង។

គ៖ បង តើបងផ្លាស់មកនៅភ្នំពេញឆ្នាំណាបង? បងចាំទេ?

ខ៖ ខ្ញុំអត់ចាំបាន ប៉ុន្តែនៅពេលដែលស្រុកខ្មែរគេចប់សង្គ្រាមអីហើយចឹង ខ្ញុំចាំបានថានៅឆ្នាំ ១៩៩០ ពួកយើងត្រូវបានបញ្ជូនឱ្យមកប្រទេសខ្មែរវិញ អញ្ចឹងឆ្នាំ១៩៩២ ខ្ញុំបានរស់នៅឯបន្ទាយមានជ័យ ២ឆ្នាំ កំឡុងពួកយើងមកដល់។ មកពីប្រទេសថៃហ្នឹង ពួកយើងរស់នៅខេត្តបន្ទាយមានជ័យ២ឆ្នាំ។ ២ឆ្នាំក្រោយមក ពួកយើងនៅឆ្នាំ១៩៩២ ពួកយើងបានមករស់នៅទីក្រុងភ្នំពេញ។

គ៖ អរគុណបង! ហើយសុំសួរបងមួយទៀតថា តើបងចាំថ្ងៃដែលបងជ្រមុជទឹកទេបង? ឆ្នាំណាបង?

ខ៖ ខ្ញុំចាំតែឆ្នាំទេ ប៉ុន្មានថ្ងៃ ឬក៏ខែភ្លេចហើយ។ ឆ្នាំ២០០០ ខ្ញុំជ្រមុជទឹកនៅឆ្នាំ២០០០។

គ៖ បងអាចចែកចាយខ្លះពីអារម្មណ៍នៃសេចក្តីជំនឿដែលបងមានចំពោះព្រះបានទេបង?

ខ៖ នៅពេលណុងមែនទេ?

គ៖ ចាស!

ខ៖ អ្វីដែលខ្ញុំចាំជាងគេកំឡុងពេលណុងគឺនៅពេលដែលខ្ញុំអាយុ១៦ឆ្នាំ។ អញ្ចឹងអាចនិយាយបានថាខ្ញុំអត់មានអីច្រើនសម្រាប់សេចក្តីជំនឿ គ្រាន់តែមានអារម្មណ៍ថាពេលដែលខ្ញុំចូលសាសនាចក្រហ្នឹង អ្វីមួយសំខាន់គឺខ្ញុំចង់ត្រឡប់មកម្តងទៀត ដោយសារនៅក្នុងផ្ទះខ្ញុំហ្នឹង លក្ខ

ណៈមានអ្វីម្យ៉ាងដែលធ្វើអត់ឱ្យ...ធ្វើឱ្យខ្ញុំមានអារម្មណ៍អត់មានភាពរីករាយអ្វីម្យ៉ាងចឹង ខ្ញុំពិបាកនិយាយ។ ពួកយើងមានម្ដាយ មានឪពុក មានបងប្អូន ប៉ុន្តែអាទំនាក់ទំនងសម្រាប់ក្រុមគ្រួសារហ្នឹង វាដូចជាមានតិច ប៉ុន្តែនៅពេលដែលខ្ញុំមកព្រះវិហារ ម្នាក់គេចាប់អារម្មណ៍ជាមួយនឹងខ្ញុំ ឬក៏អីចឹង ធ្វើឱ្យខ្ញុំកាន់តែចូលចិត្តមកព្រះវិហារ។ អញ្ចឹងនៅពេលដែលខ្ញុំអាយុ១៦ឆ្នាំ នៅឆ្នាំ២០០០ខ្ញុំជ្រមុជទឹកហ្នឹង គឺខ្ញុំចូលចិត្តតែទៅព្រះវិហារទេ ដោយសារតែមានយុវវ័យឬក៏អីហ្នឹងគាត់មកចឹង គាត់ធ្វើសកម្មភាពដ៏ល្អអីច្រើនចឹង។ អញ្ចឹងក៏បានចូលរៀនជាមួយអ្នកផ្សាយសាសនា ហើយក៏សុំម៉ាក់បន្តការទៅព្រះវិហារចឹង ហើយវាជាសំណាងល្អដែរ ដែលម្ដាយខ្ញុំគាត់ផ្ដល់ឱកាសឱ្យ ដោយសារគាត់ធ្លាប់រៀនពីសាសនាគ្រីស្ទដែរ ប៉ុន្តែគាត់អត់ទាន់ចូលទេ អញ្ចឹងគាត់ចាប់ផ្ដើមសាកល្បងឱ្យខ្ញុំធ្វើទៅ រហូតដល់ថ្ងៃជ្រមុជទឹក ពួកយើងបានសុំគាត់។ អញ្ចឹងគាត់បានអនុញ្ញាតឱ្យ ប៉ុន្តែនៅជំនាន់ហ្នឹង ខ្ញុំអត់ដឹងថាសេចក្ដីជំនឿអីទេ ប៉ុន្តែគ្រាន់តែអ្វីដែលសំខាន់ខ្ញុំចូលចិត្តទៅព្រះវិហារ នៅព្រះវិហារមានការអធិស្ឋានជាមួយនឹងគ្នា ឬក៏ចូលរួមអីធ្វើឱ្យខ្ញុំមានអារម្មណ៍ថាសប្បាយរីករាយ ឬក៏ភាពកក់ក្ដៅនៅហ្នឹង ចឹងយើងចេះតែចង់ទៅព្រះវិហារ។

គៈ បង បងបានពង្សប្រវត្តិក្រុមគ្រួសារបង?

ខៈ ហ្នឹងហើយ ខ្ញុំបានធ្វើនៅពេលដែលខ្ញុំមានឱកាសទៅព្រះវិហារបរិសុទ្ធនៅឆ្នាំ២០១០។ អញ្ចឹងខ្ញុំបានធ្វើក្រុមគ្រួសារខាងតា ខាងយាយអត់ទាន់បានធ្វើទេ។

កៈ ហើយពេលក្មេងមានបានលេងដូចជា ហ្គេមមួយ ឬក៏មានកុតក្ដាអាចចាំបានទេ?

ខៈ ហ្គេមជំនាន់ក្មេងមែនទេ?

កៈ បាទ!

ខៈ ពួកយើងកាលហ្នឹង ខ្ញុំរៀនថ្នាក់ទី៥ អ្វីដែលយើងចូលចិត្តលេងនៅជំនាន់ខ្ញុំហ្នឹងគឺលេងលោតកៅស៊ូ (សើច) មានតាំងពីខ្សែពួរ តែយើងអត់ប្រើខ្សែពួរទេ ប្រើកៅស៊ូបន្តៗគ្នាដោយសារជំនាន់ហ្នឹងអត់មានខ្សែពួរទេ យើងតកៅស៊ូតៗគ្នា យើងលោតចុះលោតឡើង ហើយនៅក្នុងពេលលោតហ្នឹងគេមានបទចម្រៀង ឬក៏ពាក្យសូត្រនៅហ្នឹង នៅពេលដែលចប់ត្រឹមហ្នឹង យើង

ត្រូវឈប់ ចឹងហាស។ ហើយមួយទៀត គេលេងបាយខុមម៉េចទេ មានប្រឡោះៗៗចឹង ប្រហែលជា៧ឬក៏១០ចឹង យើងមាននេះ សប្បាយ។ តែមួយដែលខ្ញុំចាំជាងគេគឺ ខ្ញុំពូកែជាងគេ គឺអាលោតកៅស៊ូហ្នឹង។

ក៖ ហើយចាំសូត្រទេ?

ខ៖ ចង់ឱ្យខ្ញុំសូត្រ? (សើច)

ក៖ ហ្នឹងហើយ!

ខ៖ អូខេ! អីគេអឺ...គេថា៖ "អូ! ស្រះម៉ាស៊ីៗ មីសា មីសូស្រះអុ" ស្រះអុះត្រូវតែឈប់ ស្រះអុ យើងត្រូវតែដាក់ជើងយើងហ្នឹងចន្លោះកៅស៊ូហ្នឹង ត្រូវឈប់ ត្រូវសូត្រអាហ្នឹង (សើច) ជំនាន់ខ្ញុំលេងអាហ្នឹង។

ក៖ ហើយលេងហ្នឹងនៅជិតថៃ ឬក៏លេងនៅភ្នំពេញ?

ខ៖ កាលហ្នឹងពេលខ្ញុំរៀន...អត់ទេ! ខ្ញុំត្រលប់មកពីថៃហើយ ខ្ញុំត្រលប់មកពីថៃនៅណោលដែលខ្ញុំអាយុត្រឹមតែ៧ឆ្នាំអីទេ ចន្លោះហ្នឹងហាំ អញ្ចឹងរហូតដល់នេះ ខ្ញុំចំនាយពេលវេលា នៅសាលានៅស្រុកខ្មែរ ថ្នាក់ទី៥ហ្នឹង ខ្ញុំនៅស្រុកខ្មែរនៅឡើយ។ អញ្ចឹងខ្ញុំចូលរៀននៅពេលដែលខ្ញុំអាយុបាន...អឺ...ខ្ញុំចូលរៀនថ្នាក់ទីមួយទីពីរនៅស្រុកខ្មែរ។

ក៖ មានបងប្អូនប៉ុន្មាននាក់?

ខ៖ ខ្ញុំមានបងប្អូនពីរនាក់។

ក៖ ហើយមានដូចជាបទពិសោធន៍សប្បាយៗជាមួយបងប្អូននៅពីក្មេង ដូចជា...?

ខ៖ បទពិសោធន៍ល្អនៅពេលដែលខ្ញុំចូលជាសមាជិក។ កាលមិនទាន់ចូលជាសមាជិក មានអារម្មណ៍ថាឆ្ងាយគ្នា ទោះបីជានៅផ្ទះជាមួយគ្នា មានអារម្មណ៍ថាមិនសូវជិតដិតជាមួយគ្នា ប៉ុន្តែអ្វីដែលមានការចងចាំល្អនៅពេលដែលពួកយើងនៅក្មេងៗពួកខ្ញុំទៅ...ទៅ...ទៅណាចេះ ទៅហែលទឹក។ ខ្ញុំម្នាក់ដែលអត់ចេះហែលទឹក ចឹងប្អូនខ្ញុំបានបង្រៀនខ្ញុំ ក៏អីចឹង (សើច)។

កៈ ហើយម៉ាក់ប៉ាគាត់មានមុខរបរធ្វើអី?

ខៈ អឺ...ម៉ាក់ខ្ញុំគាត់បុគ្គលិកអង្គការ ហើយប៉ាខ្ញុំគាត់មានឡានមួយរត់ គាត់រត់ឡានដឹកមនុស្សពីភ្នំពេញទៅបន្ទាយមានជ័យ។

កៈ ពេលហ្នឹងគាត់នៅបន្ទាយមានជ័យ ព្រំដែនថៃ គាត់មានមុខរបរធ្វើអីដែរ?

ខៈ កាលហ្នឹងយើងអត់មានមុខរបរជាក់លាក់ទេ។ ភាគច្រើនម៉ាក់ខ្ញុំ គាត់ធ្វើជាអ្នកលក់ដូរនំ ឬក៏គ្រឿងទេសអីផ្សេងៗចឹង នៅថៃហ្នឹង។ ហើយដោយសារនៅទីនោះយើងអត់មានការងារទេ អញ្ចឹងយើងនេះគ្រាន់តែលក់ដូរធម្មតា ព្រោះអីរាល់ការឧបត្ថម្ភ យើងបានទទួលការឧបត្ថម្ភពីប្រទេសផ្សេងសម្រាប់អ្នកដែលនៅជម្រុំហ្នឹង។ ចឹងភាគច្រើនប្រជាជននៅហ្នឹង គេអត់មានមុខរបរអីទេ។ ដោយសារម៉ាក់ខ្ញុំ ជំនាន់ហ្នឹង គាត់ចេះពេទ្យខ្លះៗចឹង គាត់ក៏ទៅចាក់ថ្នាំអីឱ្យគេហ្នឹងចឹងសម្រាប់ចំណូលពេលដែលយើងនៅថៃហ្នឹង។

កៈ ហើយឆ្ងល់ថាដូចជានៅសម័យនោះ នៅតាមព្រំដែនថៃម្ហូបវាដូចជានៅសម័យនោះ ឬក៏មានម្ហូបខុសៗគ្នា?

ខៈ នៅជម្រុំ ខ្ញុំធំដឹងក្ដីឡើង ខ្ញុំស្គាល់តែអាហារកំប៉ុងទេ។អាហារស្រស់គឺពួកយើងអត់សូវមានម៉ង ដោយសារវាឆ្ងាយ។ សូម្បីតែយើងនៅជាយដែនថៃ ប៉ុន្តែយើងមិននៅជិតខេត្តថៃទេ ប៉ុន្តែបើនៅក្នុងខេត្តថៃ យើងស្រួលរកទេ ប៉ុន្តែយើងរស់នៅគេហៅថាតំបន់វាល គេហៅវាលរហោស្ថាន វាលតែម៉ង ហើយយើងមានជម្រុំមួយដែលមានប្រជាជនខ្មែររស់នៅដូចគ្នាទេ ហើយរកអាហារគឺពួកយើងអត់បានបន្លែស្រស់ៗ មានតែអាហារកំប៉ុងម៉ង ពិសេសខ្ញុំចាំជាគេ ញ៉ាំតែត្រីខទេ។ ត្រីខដាក់នៅក្នុងកំប៉ុងហ្នឹង ចឹងពួកយើងអត់សូវ...វាមានអាហារដែលគេលក់ដូចជាសាច់សាច់ជ្រូក ឬក៏សាច់គោ ប៉ុន្តែវាកម្រមាន វាមិនសូវសម្បូរប៉ុន្មានទេ ភាគច្រើនយើងញ៉ាំអាហារដែលជាអាហារកំប៉ុងច្រើន។

កៈ ហើយដូចជាតាមព្រំដែនថៃដូចជាសម្បូរសត្វផ្សេងៗ ឬក៏ស្ថានភាពយ៉ាងម៉េចដែរ?

ខ៖ តំបន់ដែលគេឱ្យយើងនៅ ជាតំបន់ដែលមានសុវត្ថិភាព វាមិនមានសត្វព្រៃសាហាវៗអីទេ។ គ្រាន់តែថាពេលយើងដើរកាត់ព្រៃអីចឹង វាមានសត្វយំ យើងប្រយ័ត្នសម្រាប់ សម្រាប់អីចឹងហាំ ប៉ុន្តែបើកន្លែងដែលគេជ្រើសរើសឱ្យយើងនៅ ជាកន្លែងដែលមានសុវត្ថិភាព វាមិនមានសត្វសាហាវអីច្រើនទេ។

ក៖ ដូចជាសត្វស្វាអី?

ខ៖ អឺម...ដូចអត់ដែលឃើញផង (សើច) ដោយពួកយើងកម្រធ្វើដំណើរកាត់ព្រៃណាស់ គ្រាន់តែថាយើងនៅតំបន់របស់យើងចឹងហាំ។ បើយើងធ្វើដំណើរ យើងប្រើប្រាស់ឡានអីចឹង ដល់ពេលដើរគ្រាន់តំបន់ដែលវាផ្លូវពិបាកចឹងបានយើងដើរទៅម៉ង។ ភាគច្រើនកាលធ្វើដំណើរចេញចូល យើងប្រើប្រាស់រថយន្ត ប្រើប្រាស់ឡាន តែបើថាតំបន់ផ្លូវវាអត់ស្អាតទេ ផ្លូវជាផ្លូវដីលំផ្លូវវាអត់មានកៅស៊ូអី ពេលពិបាកយើងចុះដើរឬក៏អីចឹងហាំ។ ចឹងកំឡុងពេលចុះដើរខ្ញុំបានឮបានឃើញអីច្រើនចឹង កំឡុងពេលខ្ញុំនៅតូចហ្នឹង។

ក៖ ហើយមានគ្រោះថ្នាក់ ដូចជាគ្រាប់មីនច្រើនសម្បូរទេ?

ខ៖ សម្បូរ! កន្លែងហ្នឹងពេលហ្នឹង យើងប្រយ័ត្នសម្រាប់អាហ្នឹង។ ការពិតនៅពីតូចខ្ញុំអត់សូវបានចងចាំទេ ប៉ុន្តែភាគច្រើនអ្វីដែលខ្ញុំដឹង ពេលដែលយើងដើរកាត់ព្រៃ យើងត្រូវការពាក្យខ្មែរមួយគេហៅថាមេខ្យល់ អ្នកដែលស្គាល់តំបន់ហ្នឹង ស្គាល់ផ្លូវហ្នឹងហាំ បើយើងដើរខុសវាអាចជាន់ ឬក៏អីចឹង គេបារម្ភអាហ្នឹងដែរ។

ក៖ ចឹងមានស្គាល់គេដែលមានបាត់ជើងអី?

ខ៖ អត់ទេអាហ្នឹង ប្រហែលជាខ្ញុំនៅតូចពេកអត់ដឹង។ ប៉ុន្តែគ្រាន់អ្វីដែលសំខាន់ នៅពេលដែលយើងដើរកាត់ព្រៃឬក៏ឆ្លងពីតំបន់មួយយើងត្រូវចាំបាច់ត្រូវការមេខ្យល់អ្នកដែលនាំផ្លូវយើង បើមិនចឹងទេ អាចវង្វេងឬក៏ប៉ះពាល់អីចឹងណាំ។

គ៖ បងសុំសួរទាក់ទងកាលបងនៅក្មេងហាំ ម៉ាក់បងដែលនិយាយអំពីតាឬក៏យាយ ពីប្រវត្តិគាត់ម៉េចៗដែរ។

ក៖ តាមពិតតាំងពីជំនាន់ប៉ុល ពត មកពួកគាត់បែកគ្នាម៉ង អញ្ចឹងកាលដឹង...គាត់ធ្លាប់រស់នៅ... ម៉ាក់ខ្ញុំ គាត់បែកពីតាយាយខ្ញុំ ពេលគាត់អាយុ២០ឆ្នាំ ១៩ឆ្នាំដូចគ្នា។ អញ្ចឹងមានន័យថាការដឹងពីតាយាយ ខ្ញុំអត់ដឹង គាត់អត់សូវដែលបាននិយាយទេ។ ខ្ញុំបានដឹងច្បាស់នៅពេលដែលខ្ញុំទៅរកពង្សប្រវត្តិហ្នឹងដោយខ្លួនឯង។ ខ្ញុំបានស្ដាប់ឮពីបងប្អូនចឹងណា៎ ប៉ុន្ដែម្ដាយរបស់ខ្ញុំគាត់អត់សូវ...គាត់កម្រ...គាត់ធ្លាប់តែនិយាយឈ្មោះ ហើយកាលខ្ញុំនៅតូចហ្នឹង ខ្ញុំនៅជាមួយយាយរបស់ខ្ញុំ យាយហ៎ា យាយខាងម្ដាយហ្នឹង។ អញ្ចឹងខ្ញុំអាចដឹងពីគាត់ ប៉ុន្ដែបើសិនជាតាខ្ញុំហ្នឹង គាត់ស្លាប់កាលពីជំនាន់ ប៉ុល ពត ហើយ។ ចឹងអ្វីដែលសំខាន់ គាត់គ្រាន់តែប្រាប់ថាតាគាត់បញ្ចុះនៅកន្លែងណា នៅអីតែប៉ុណ្ណឹង អត់បាននិយាយអំពីនេះ គ្រាន់តែប្រាប់ពីការងាររបស់តាហ្នឹង ដឹងគាត់ធ្វើអីខ្ញុំភ្លេចបាត់ទៀតហ្នឹង អត់សូវលម្អិតប៉ុន្មានទេ តែបើសិនជាយាយខ្ញុំធ្លាប់រស់នៅជាមួយគាត់ អញ្ចឹងខ្ញុំអាចដឹងពីគាត់ខ្លះៗបានច្រើន។

គ៖ បងតើអ្វីដែលបងចាំពីម៉ាក់បងច្បាស់ហ៎ា? បងចាំទេ? ដូចថាម្ហូប គាត់ធ្វើឆ្ងាញ់ ឬក៏យ៉ាងម៉េច?

ក៖ ការចងចាំដែលល្អ ដែលខ្ញុំមានចំពោះម៉ាក់ខ្ញុំ គឺគាត់ធ្វើម្ហូប ដោយសារម៉ាក់ខ្ញុំ គាត់រវល់ការងារពីច័ន្ទដល់សុក្រ ដល់ពេលសៅរ៍អាទិត្យ ទោះបីគាត់រវល់ម៉េចក៏ដោយ គាត់កាន់កន្ត្រកគាត់ទៅផ្សារ ហើយមកវិញ កន្ត្រកហ្នឹងពេញដោយអាហារ ហើយគាត់តែងតែចំអិនអាហារឱ្យកូនរាល់ថ្ងៃសៅរ៍ និង ថ្ងៃអាទិត្យ ដែលយើងសម្រាកហ្នឹង។ ចឹងអាហារដែលធ្វើពីម្ដាយ ធ្វើឱ្យពួកខ្ញុំចងចាំរហូតដល់ឥឡូវ។ ជាពិសេសអាហារដែលគាត់ពូកែធ្វើជាងគេ សម្លកកូរ ហើយបង្អែមដែលគាត់បង្រៀនខ្ញុំឱ្យធ្វើ គឺអាបង្អែមចេកខ្ទិះហ្នឹងឯង។ ធម្មតាចេកខ្ទិះ គេហៅថាយើងមានរូបមន្តផ្សេងគ្នា អញ្ចឹងរបៀបបង្រៀនរបស់ម៉ាក់ខ្ញុំហ្នឹង ខុសពីអាចេកខ្ទិះដែលយើងទៅញ៉ាំខាងក្រៅហ្នឹង គឺគាត់ធ្វើឆ្ងាញ់ គាត់បានបង្រៀនអាហ្នឹងមួយ ហើយក្នុងចំនោមបង្អែមទាំងអស់ ខ្ញុំចេះតែអាហ្នឹងមួយជាងគេ ដោយសារម្ដាយខ្ញុំ គាត់បង្រៀន គាត់បង្រៀនខ្ញុំ ឱ្យខ្ញុំធ្វើអាហ្នឹង។

គ៖ បង តើបងអាចចែកចាយថាបងប្រៀបធៀបថាពីបងនៅក្មេង និង បងឥឡូវ តើមានភាពផ្លាស់ប្ដូរអីដែលបងគិតថា ជាកំណាត់សម្គាល់អីអត់បង?

ខ៖ អឺ...ផ្លាស់ប្តូរ...ផ្លាស់ប្តូរអីគេ?

គ៖ ចង់និយាយថាកាលយើងនៅក្មេង ហើយឥឡូវ តើបងឃើញថា យើងផ្លាស់ប្តូរ ឬក៏វានៅតែភាពដដែល?

ខ៖ ធម្មតា បើយើនិយាយពីក្មេង និង ឥឡូវ យើងមានការផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំ គ្រាន់ថាកាលពីក្មេងយើងរស់នៅក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយ។ នៅពេលដែលយើងធំ មកដល់វ័យហ្នឹង យើងរស់នៅឯករាជ្យដោយខ្លួនឯងចឹងទៅណា។

គ៖ អញ្ចឹងបងបានរៀនច្រើនពីសិក្ខាបទរបស់ព្រះ ចឹងបងចង់ចែកចាយនៅពេលដែល...បងបើសិនជាខ្ញុំសុំសួរបងថាបើសិនជាបងមានកូននៅពេលថ្ងៃក្រោយចឹង តើបងមានពាក្យអីដែលចង់និយាយទៅពួកគាត់? ចង់និយាយថា យើងមានពាក្យអី នៅពេលដែលយើងមានកូន បងមានពាក្យអីដែលផ្តាំទៅពួកគាត់ នៅពេលដែលបងចង់ចែកចាយ មានសារលិខិតអីសម្រាប់ពួកគាត់ទេ។

ខ៖ ការពិតតាំងពីខ្ញុំដឹងក្តីមកដល់ឥឡូវ ខ្ញុំដឹងថាតាមរយៈការដើរនៅតាមព្រះសិក្ខាបទរបស់ព្រះនឹងអាចជួយដល់ពួកគេនៅ...នាំពួកគេនៅសុភមង្គល ហើយនិងសន្តិភាពក្នុងចិត្ត។ ចឹងបើខ្ញុំមានកូន ខ្ញុំចង់ឱ្យកូនៗរបស់ខ្ញុំហ្នឹងរក្សាការប្រតិបត្តិតាមព្រះសិក្ខាបទដែលព្រះបានបង្រៀនដូចជាខ្ញុំបានរៀនពីព្រះដូចគ្នាចឹងដែរ។ ដោយសារខ្ញុំបានទទួលបទពិសោធថា នៅពេលដែលយើងធ្វើតាមបញ្ញាត្តិរបស់ព្រះ សន្តិភាពមានក្នុងចិត្តយើង យើងរស់នៅដោយភាពរីករាយ។ នៅក្នុងជីវិតរបស់យើង អ្វីដែលសំខាន់ ខ្ញុំចង់ឱ្យកូនរបស់ខ្ញុំទទួលនូវអ្វីដែលខ្ញុំមានអារម្មណ៍ដូចគ្នាចឹងផងដែរ។

គ៖ មានតែប៉ុណ្ណឹង បងមានអីបន្ថែមទៀតទេ? អត់ទេ?

ខ៖ ដោយសារអត់ទាន់មានកូនផង វាពិបាក (សើច)

គ៖ អញ្ចឹងខ្ញុំប្រហែលជាសាកសួរបងថែមទៀត ព្រោះយើងនៅ...តើបងចង់ចែកចាយអ្វីដែលបងចង់ចែកចាយបន្ថែមទៀតទាក់ទងទៅនឹងសេចក្តីជំនឿរបស់ព្រះ?

ខ៖ សេចក្ដីជំនឿ វាអត់ជាក់លាក់ សេចក្ដីជំនឿអីគេ?

គ៖ អត់មាន?

ខ៖ វាអត់ជាក់លាក់...

ក៖ ខ្ញុំសួរសំណួរមួយទៀត បទពិសោធដែលពិបាកជាងគេក្នុងជីវិតរបស់បងស្រី ប្រហែលជាបទពិសោធអីគេដែរ?

ខ៖ ពិបាកជាងគេ...បទពិសោធដែលល្អ ឬ អាក្រក់?

ក៖ ដូចជាពេលវេលាមួយដែលពិបាកខ្លាំង?

ក៖ ពិបាកជាងគេ! នៅពេលដែលបងប្រុសខ្ញុំគាត់នេះ...(សើច) អឺ...ដោយសារខ្ញុំរស់នៅជាមួយនឹងប្អូនប្រុស ចឹងវាជាបទពិសោធមួយដែលពិបាក មានន័យថាឆ្លងកាត់នៅពេលដែលអឺ...ប្អូនប្រុសរបស់ខ្ញុំ យប់មួយគាត់សម្រេចចិត្តជ្រើសរើសហ្គេមជាងជ្រើសរើសអ្នកផ្ទះ។ ចឹងគាត់បានចេញពីផ្ទះ ទៅលេងវាបីថ្ងៃ ចឹងជាបទពិសោធមួយដែលខ្ញុំពិបាកឆ្លងកាត់ជាងគេ ដោយសារអារម្មណ៍ខ្ញុំចំពោះប្អូនគឺស្រឡាញ់ ស្រឡាញ់គាត់ក្នុងនាមជាបងស្រីម្នាក់ អញ្ចឹងខ្ញុំបានថែរក្សាគាត់បានច្រើនជាងគេ អាចនិយាយបានថាម្ដាយរបស់ខ្ញុំគាត់អត់សូវមានឱកាសថែរក្សាទេ ចឹងអារម្មណ៍នៃសេចក្ដីស្រឡាញ់ចំពោះប្អូនប្រុស ហើយឃើញគាត់នៅពេលដែលគាត់ជ្រើសរើសទៅលេងហ្គេមទោះបីគាត់ដឹងថាគាត់ត្រូវទទួលពិន័យ គាត់នៅតែទៅ ចឹងមានអារម្មណ៍ថាខកចិត្ត ហើយខឹងគាត់កន្លែងហ្នឹងខ្លាំងមែនទែន។ វាពិបាកឆ្លងកាត់ ហើយធ្វើឱ្យខ្ញុំអត់គេងទេមួយយប់ហ្នឹង អង្គុយចាំប្អូនក៏អីហ្នឹង។ ជាពេលវេលាមួយដែលវាពិបាកឆ្លងកាត់ជាងគេនៅពេលដែលឃើញប្អូនគាត់ជ្រើសរើសលេងហ្គេមច្រើនជាងក្រុមគ្រួសារ។

ក៖ ហើយចុះបទពិសោធសប្បាយរីករាយជាងគេមាន?

ខ៖ នៅពេលដែលខ្ញុំនៅក្នុងព្រះវិហារបរិសុទ្ធ សប្បាយរីករាយជាងគេ។ នៅពេលដែលខ្ញុំបានធ្វើពិធីការសម្រាប់គ្រួសារខ្ញុំ ខ្ញុំបានទទួលអារម្មណ៍ថាពួកគាត់ដឹងដែរ អញ្ចឹងខ្ញុំមានអារម្មណ៍សប្បាយមែនទែន។

ក៖ ហើយជំនាន់ក្រោយ ដូចមានកូនចៅ ចៅទួតអី បងស្រីចង់ឱ្យដូចជាចៅ និង ចៅទួតដឹង បងស្រីចង់ឱ្យដឹងអីអំពីបងស្រី?

ខ៖ ដឹងថាខ្ញុំជាអ្នកដែលញៀនក្នុងការមកព្រះវិហារ ចូលចិត្ត ចូលចិត្តមកព្រះវិហារ ទោះបីមកដល់ឥឡូវក៏ដោយ។ ទោះបីមានស្ថានការអីកើតឡើងក៏ដោយគឺខ្ញុំនៅតែមានអារម្មណ៍ថា អាការចូលចិត្តមកព្រះវិហារគឺខ្ញុំអត់បាត់អាហ្នឹងសោះ មានន័យថាលក្ខណៈញៀន ញៀននៅក្នុងការមកព្រះវិហារ (សើច) អញ្ចឹងខ្ញុំចង់ឱ្យកូនចង់ខ្ញុំដឹងថាយាយគាត់ ឬក៏ម្ដាយគាត់ជាអ្នកដែលចូលចិត្តមកព្រះវិហារខ្លាំងមែនទែន។ អត់ដឹងថាមូលហេតុអីគ្រាន់ថា មកព្រះវិហារមានអារម្មណ៍សប្បាយរីករាយ មានអារម្មណ៍នៃភាពកក់ក្ដៅ អញ្ចឹងចង់ឱ្យគាត់មកដូចគ្នាផងដែរ។

ក៖ ហើយម្ហូបដែលស្រឡាញ់ជាងគេអីគេ?

ខ៖ ខ្មែរ ខ្ញុំចូលចិត្តសម្លកកូរ មូលហេតុនៃការចូលចិត្តគឺសម្លហ្នឹង ម្ដាយរបស់ខ្ញុំគាត់ធ្វើឆ្ងាញ់ជាងគេ។ ខ្ញុំមានការចងចាំពីតូច ហើយមកដល់ឥឡូវខ្ញុំឃើញថាម្ហូបហ្នឹងគឺមានរបស់អីចូលក្នុងហ្នឹងច្រើន មានបន្លែ មានសាច់ មានត្រីក្នុងណុងច្រើន អញ្ចឹងខ្ញុំចូលចិត្តពិសេសដាក់អង្ករលីងក្នុងហ្នឹង។

ក៖ ហើយបទចម្រៀង ឬបទភ្លេងចូលចិត្ត?

ខ៖ ប្រភេទណាហ៎? បទចម្រៀងប្រភេទណាហ៎?

គ៖ ចាស!

ខ៖ ខ្ញុំចូលចិត្តបែបយឺត បទចម្រៀងយឺតៗ។

ក៖ ដូចជាតាមឡានក្រុង គេបើកតាមឡានក្រុង?

ខ៖ ហ្នឹងហើយ យឺតៗស្ដាប់ ជាពិសេសចម្រៀងនិយាយអំពីធម្មជាតិអីចឹង (សើច)

ក៖ ដូចជានៅបាត់ដំបងអី

ខ៖ ហ្នឹងហើយ! និយាយខេត្តបាត់ដំបង និយាយពីខេត្តកំពង់ចាមពីអីចឹង ស្ដាប់អាហ្នឹងបានល្អ។

កៈ អូខេ! អញ្ជើញតែប៉ុណ្ណឹង!

គៈ អរគុណបង!

ខៈ ចាស!